ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា
# លោកជំទាវ ជា សិរី
# អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងកិច្ចប្រជុំក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ (ក្រុម "ង")

ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤
សាលប្រជុំស្ទឹងបរិបូរណ៍ ជាន់ទី២ ធនាគារជាតិនៃកម្ពុជា អគារសែនសុខ

*សូមគោរព៖*

- *អ្នកឧកញ៉ា* ***គិត ម៉េង*** *សហប្រធានក្រុមការងារ "ង"*
- *ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាទីគោរពរាប់អាន!*

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយនិងសូមស្វាគមន៍ *អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី* ដែលបានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ (ក្រុម "ង") សម្រាប់ឆ្នាំ២០២៤ នេះ។ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុនិងអាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានចូលរួមគាំទ្រយ៉ាងសកម្មចំពោះការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីវិបត្តិកូវីដ-១៩ និងភាពតានតឹងនៃសេដ្ឋកិច្ច ដោយភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល។ ខ្ញុំសូមជម្រាប អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជ្រាបថា គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៤ ប្រព័ន្ធធនាគារនៅកម្ពុជាដែលរួមមាន វិស័យធនាគារ វិស័យមីក្រូហិរញ្ញវត្ថុ និងវិស័យភតិសន្យាហិរញ្ញវត្ថុមានទ្រព្យសកម្មសរុបចំនួន ៨៧,៤ ប៊ីលានដុល្លារអាមេរិក ឥណទានអតិថិជន ៥៨,៦ ប៊ីលានដុល្លារអាមេរិក និងប្រាក់បញ្ញើអតិថិជន ៥២,៤ ប៊ីលានដុល្លារអាមេរិក។ ស្របពេលដែលសេដ្ឋកិច្ចសកលកំពុងបន្តជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន សេដ្ឋកិច្ចកម្ពុជាបន្តទទួលរងផលប៉ះពាល់អវិជ្ជមានដែលបង្ហាញឱ្យឃើញតាមរយៈ ១/-កំណើនយឺតនៃឥណទានទៅវិស័យអចលនទ្រព្យ ២/-ការធ្លាក់ចុះនៃគុណភាពឥណទាន និង ៣/-ការកើនឡើងនៃសកម្មភាពធនាគារស្រមោល និងភាពមិនប្រក្រតីផ្សេងៗរវាងអ្នកទិញនិងអ្នកអភិវឌ្ឍន៍អចលនវត្ថុ។ កត្តាទាំងនេះបានបន្តជះឥទ្ធិពលអវិជ្ជមានមកលើប្រព័ន្ធធនាគារនៅកម្ពុជា ដែលជាក់ស្តែងកំណើនទ្រព្យសកម្មនិងឥណទានអតិថិជននៅក្នុងប្រព័ន្ធធនាគារបានបន្តបង្ហាញសញ្ញាថមថយមកត្រឹម ៧,៥% និង ៤,៣% រៀងគ្នា ក្នុងខែមិថុនា ឆ្នាំ២០២៤ ដោយថយចុះពី ៨,៨% និង ៩,២% រៀងគ្នា ក្នុងខែមិថុនា ឆ្នាំ២០២៣។ ដោយឡែក ប្រាក់បញ្ញើ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

អតិថិជនមានកំណើន ១៦,៩% ខ្ពស់ជាងគ្រាដូចគ្នានៃឆ្នាំមុន ៧,៦% បន្ទាប់ពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានងាកមកស្វែងរកប្រភពទុនក្នុងស្រុក។ លើសពីនេះ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថាន ក៏មានភាពថមថយ។

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅវិមានសន្តិភាព មានរៀបចំ "វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ បន្ទាប់មករាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ តាមរយៈសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី លទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩ ដែលក្នុងនោះត្រង់ចំណុច ៨ "វិស័យធនាគារនិងហិរញ្ញវត្ថុ" បានប្រគល់ភារកិច្ចជូនធនាគារជាតិនៃកម្ពុជាដូចខាងក្រោមៈ

ក. អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនត្រឹមកម្រិត ១,២៥% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

ខ. អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រឹមកម្រិត ៧% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

គ. អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ ចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្នដោយមិនចាំបាច់ធ្វើសំវិធានធន រយៈពេល ១២ខែ និង

ឃ. លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ ចំពោះវិស័យអចលនទ្រព្យ ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្នដោយត្រូវអនុវត្តម៉ឺងម៉ាត់តាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានត្រូវសិក្សានិងវិភាគច្បាស់លាស់អំពីស្ថានភាពរបស់អតិថិជន និងផលប៉ះពាល់នៃឥណទានរបស់អតិថិជននោះចំពោះប្រព័ន្ធទាំងមូល ព្រមទាំងអាចស្នើសុំការពិភាក្សាជាមួយធនាគារជាតិនៃកម្ពុជាដើម្បីពិចារណាអំពីវិធានការអនុគ្រោះតាមករណីជាក់ស្តែងបន្ថែមទៀត។

ជាក់ស្តែង តាមរយៈអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនខាងលើ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានអនុវត្តវិធានការទាំងនេះ តាមរយៈការជូនដំណឹងអំពីការផ្តល់ការអនុគ្រោះផ្នែកបទប្បញ្ញត្តិនិងការដាក់ចេញនូវសារាចរណែនាំ ស្តីពី ការរៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប។

បន្ទាប់ពីបានដាក់ចេញវិធានការខាងលើ ធនាគារជាតិនៃកម្ពុជា តែងតែតាមដានការអនុវត្ត និងបានរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តខាងលើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នបូកសរុបរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់។ លើសពីនេះ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានចាត់តាំងតំណាងចូលរួមកិច្ចប្រជុំបូកសរុបរបាយការណ៍ស្តីពី វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលដាក់ចេញដោយ "វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩" ដែលកិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម **ជា វុទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីពិនិត្យពិភាក្សាលើវឌ្ឍនភាពនៃការអនុវត្ត វិធានការសរុបមានចំនួន ១៨៨ ដែលក្នុងនោះធនាគារជាតិនៃកម្ពុជា បានអនុវត្តពេញលេញនូវវិធានការទាំង ៥ ដែលវេទិកាបានប្រគល់ជូន។ ជាក់ស្តែង គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ ឥណទានរៀបចំឡើងវិញចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប មានចំនួន ១៧២,២៩ លានដុល្លារអាមេរិក ដែលបានរៀបចំឡើងវិញជូនអតិថិជន ៥.៦៤២ នាក់។

លើសពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បានលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់បង្កើនប្រសិទ្ធភាពក្នុងការផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវ សំដៅពង្រឹងភាពធន់នឹងហានិភ័យរបស់គ្រឹះស្ថាននីមួយៗ ដើម្បីអាចរក្សាបាននូវស្ថិរភាពប្រព័ន្ធធនាគារ និងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា មានគោលបំណងទាញចំណាប់អារម្មណ៍ឱ្យគ្រឹះស្ថានទាំងអស់យកចិត្តទុកដាក់ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ និងការរក្សាបាននូវសន្ទនីយភាព និងដើមទុនគ្រប់គ្រាន់ ជាពិសេសក្នុងអំឡុងពេលដែលស្ថានភាពសេដ្ឋកិច្ចអំណោយផល ពីព្រោះបើយើងពិនិត្យលើវដ្តនៃសេដ្ឋកិច្ចតែងតែមានការធ្លាក់ចុះឬបញ្ហាប្រឈមកើនមាន បន្ទាប់ពីមានកំណើនឬស្ថានភាពសេដ្ឋកិច្ចអំណោយផលជាប់គ្នាច្រើនឆ្នាំ ដែលតម្រូវឱ្យគ្រឹះស្ថាននីមួយៗគិតគូរពីបញ្ហានេះនិងត្រៀមខ្លួនទុកជាមុន ចៀសវាងការពឹងផ្អែកខ្លាំងលើសលប់លើអាជ្ញាធរ ក៏ដូចជារដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាក្នុងគ្រាមានវិបត្តិ។

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តតាមដានស្ថិរភាពប្រព័ន្ធធនាគារដោយយកចិត្តទុកដាក់ដើម្បីពិចារណាលើវិធានការអនុគ្រោះចំពោះឥណទានទៅវិស័យសេដ្ឋកិច្ចរូបវន្តផ្សេងទៀត ដែលមានផលប៉ះពាល់អវិជ្ជមានជាប្រព័ន្ធ ព្រមទាំង បន្តដោះស្រាយបញ្ហាផ្សេងៗទៀតដែលវិស័យធនាគារបាន ឬអាចនឹងប្រឈម ក្នុងគោលបំណងបន្តរក្សាស្ថិរភាពប្រព័ន្ធធនាគារ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ជាពិសេសក្នុងស្ថានភាពភូមិសាស្ត្រនយោបាយបច្ចុប្បន្ន។ ក្នុងន័យនេះ ថ្ងៃនេះយើងនឹងពិភាក្សាពី "វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩" ដូចបានជម្រាបជូនខាងលើ ជាពិសេសបញ្ហាប្រឈមផ្សេងៗ ដែល

បញ្ហាប្រឈមរបស់ផ្នែកឯកជនវិស័យសេវាធនាគារ និងហិរញ្ញវត្ថុ អាចរួមមាន៖ ១/-អនុបាតភាពគ្រប់គ្រាន់នៃដើមទុន (អនុបាតសាធនភាព) ២/-ទ្រនាប់ដើមទុន ៣/-អាត្រាប្រាក់បម្រុងកាតព្វកិច្ច ៤/-ឥណទានរៀបចំឡើងវិញចំពោះវិស័យទេសចរណ៍ ៥/-ឥណទានរៀបចំឡើងវិញចំពោះវិស័យផ្សេងទៀត ៦/-បញ្ហាឥណទានដែលផ្តល់ដោយបុរី ៧/-ការងារបន្តនិងបញ្ហាប្រឈមមួយចំនួនផ្សេងទៀត។

ខ្ញុំសូមអង្គប្រជុំពិនិត្យពិភាក្សា ដើម្បីបន្តដោះស្រាយបញ្ហាដែលកំពុង និងអាចកើតមានក្នុងវិស័យធនាគារ ប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់។

**សូមអរគុណ!**